ANNA & ASSOCIATES
Law Office

# ព្រឹត្តិបត្រគតិយុត្តខ្លីៗប្រចាំខែ
# ខែធ្នូ ឆ្នាំ២០២១
# ភាគ ២៦

## ការរៀបអាពាហ៍ពិពាហ៍ ឬការរៀបការ

### ១. តើអ្វីនៅជាការរៀបអាពាហ៍ពិពាហ៍?

ការរៀបអាពាហ៍ពិពាហ៍ ឬការរៀបការ គឺជាពិធីមួយដែលរៀបចំឡើងសម្រាប់ផ្សំផ្គុំរវាងបុរស និងនារីដែលដល់នីតិភាព ឬគ្រប់វ័យរៀបការក្នុងការបង្កើតក្រុមគ្រួសារថ្មី ដើម្បីពង្រីកចង្កោមញាតិ ក៏ដូចជាបន្តពូជពង្សវង្សត្រកូល។ ការរៀបអាពាហ៍ពិពាហ៍ ភាគច្រើនត្រូវបានរៀបចំឡើងជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់តាំងពីបុរាណមក ដែលគេអាចចាត់ទុកវាជាផ្នែកមួយនៃសីលធម៌សម្រាប់សង្គមខ្មែរផងដែរ ដោយប្រកាសជាសាធារណៈថាបុរស និងនារីនោះ គឺជាស្វាមី-ភរិយានឹងគ្នាដោយមានការដឹងឮក៏ដូចជាទទួលស្គាល់ពីសាធារណៈជន និងសាច់ញាតិបងប្អូនជាដើម។ ប្រសិនបើអាពាហ៍ពិពាហ៍គ្រាន់តែគោរពទៅតាមប្រពៃណី គឺវាមិនមានអានុភាពតាមផ្លូវច្បាប់គ្រប់គ្រាន់ក្នុងការការពារភាគីប្ដី-ប្រពន្ធទាំងសងខាងនោះទេ ដោយតម្រូវឱ្យភាគីប្ដី-ប្រពន្ធធ្វើការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍។ តើកិច្ចសន្យាកិច្ចអាពាហ៍ពិពាហ៍គឺជាអ្វី?

កិច្ចសន្យាអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាឱឡារិកមួយដែលធ្វើឡើងដោយបុរស និងនារីម្នាក់ដែលប្ដេជ្ញា ថាខ្លួននឹងរួមសមគ្គសង្វាស ឬរួមរស់ជាមួយគ្នាតាមបញ្ញត្តិនៃច្បាប់ហើយមិនអាចរំលាយទៅវិញដោយឯកឯងឡើយ និងមានអានុភាពពេញលេញតាមច្បាប់បានលុះត្រា អាពាហ៍ពិពាហ៍នោះធ្វើឡើងតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។ ចំពោះលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍ ដែលចែងនៅក្នុង មាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បុរស និងនារីមិនទាន់ដល់នីតិភាព (អាយុក្រោម ១៨ ឆ្នាំ) មិនអាចរៀបអាពាហ៍ពិពាហ៍បានទេ លុះត្រាតែបុរស ឬនារីម្ខាងដល់នីតិភាព និងបុគ្គលម្ខាងទៀតមានអាយុមិនក្រោម ១៦ ឆ្នាំ ហើយមានការយល់ព្រម ពីអ្នកមានអំណាចមេបា ឬអាណាព្យាបាលរបស់អនីតិជននោះ ។

**បច្ចុប្បន្នភាពគតិយុត្ត**

*ក្នុងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ ក្រសួងពាណិជ្ជកម្មបានចេញសេចក្ដីជូនដំណឹងលេខ ២៩០៨ ព.ណ.ចបព ស្ដីពីការពន្យាពេលការផាកពិន័យ ចំពោះការដាក់ពាក្យស្នើសុំនូវលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមរយៈប្រព័ន្ធអេឡិចត្រូនិករហូតដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ជាកំណត់។ ចំពោះពាក្យស្នើសុំ បែបបទ លក្ខខណ្ឌ និងឯកសារអាចតម្រូវឱ្យទាញយកបាន តាមគេហទំព័រ* www.ecommercelicensing.moc.gov.kh *ឬតាមរយៈគេហទំព័រផ្ទាល់របស់ក្រសួងពាណិជ្ជកម្ម* www.moc.gov.kh *បុគ្គលស្នើសុំអាចដាក់ពាក្យស្នើសុំដោយផ្ទាល់ទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ឬក៏អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។*

### ២. តើត្រូវបំពេញនីតិវិធីអ្វីខ្លះដើម្បីទទួលបានអាពាហ៍ពិពាហ៍ស្របច្បាប់?

ដើម្បីទទួលបានអាពាហ៍ពិពាហ៍ស្របច្បាប់បុរស និងនារីត្រូវបំពេញនីតិវិធីដូចខាងក្រោម៖

**១. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍**

សមីខ្លួនត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅកាន់មន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់នៃលំនៅដ្ឋានខាងនារី។

↓

**២. ការប្រកាសជាសាធារណៈ**

បន្ទាប់ពីដាក់ពាក្យរួចហើយ មន្ត្រីឃុំ/សង្កាត់នឹងចេញប័ណ្ណប្រកាសបិទផ្សាយអាពាហ៍ពិពាហ៍ ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និងសាលាឃុំ/សង្កាត់នៃលំនៅស្ថានសមីខ្លួនទាំងសងខាងក្នុងរយៈពេល ១០ថ្ងៃ ដើម្បីឱ្យតតិយជនដែលពាក់ព័ន្ធនៅក្នុងរឿងនេះអាចតវ៉ាបាន។ បន្ទាប់ពីរយៈពេល ១០ ថ្ងៃ ប្រសិនបើពុំមានពាក្យប្ដឹងទាស់អ្វីទៅលើអាពាហ៍ពិពាហ៍នេះទេ សមីខ្លួនអាចរៀបអាពាហ៍ពិពាហ៍បាន។

↓

***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្ដល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្ដោតសំខាន់ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្ដល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

### ៣. ចុះកិច្ចសន្យា និងចុះសំបុត្រអាពាហ៍ពិពាហ៍

សមីខ្លួនទាំងសងខាងត្រូវទៅចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ចំពោះមុខមន្រ្តីអត្រានុកូលដ្ឋាននៃលំនៅដ្ឋានខាងនារី បន្ទាប់ពីរៀបចំពិធីរួចរាល់ ដោយត្រូវមានបុគ្គលគ្រប់អាយុការចំនួនពីររូបធ្វើជាសាក្សីដើម្បីបញ្ជាក់ពីការដឹងឮលើការចុះកិច្ចសន្យានេះ។ បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋានធ្វើការសាកសួរ ស្រង់ព័ត៌មានផ្ទាល់ខ្លួនរបស់ភាគីទាំងសងខាង និងចុះសៀវភៅអាពាហ៍ពិពាហ៍ជូនភាគីទាំងពីរ បន្ទាប់ពីនេះមន្ត្រីអត្រានុកូលដ្ឋាននឹងប្រគល់ជូនសមីខ្លួនប្តី-ប្រពន្ធនូវសំបុត្រអាពាហ៍ពិពាហ៍ (អេតាស៊ីវិល) ច្បាប់ដើម និងធ្វើសេចក្តីចម្លងតាមការស្នើសុំរបស់សមីខ្លួនសម្រាប់ទុកក្នុងការប្រើប្រាស់។

## ៣. តើចំណងភាតព្វកិច្ចតាមផ្លូវច្បាប់អ្វីខ្លះដែលនឹងកើតមានឡើងរវាងសហព័ទ្ធក្រោយពេលរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់?

ប្តី-ប្រពន្ធ ឬអាចហៅតាមន័យច្បាប់ថាសហព័ទ្ធ មានកាតព្វកិច្ចក្រោយពេលរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ដូចជា៖

- នៅក្នុងគ្រួសារប្តី-ប្រពន្ធត្រូវមានសិទ្ធិស្មើគ្នា
- ប្តី-ប្រពន្ធ មានករណីកិច្ចស្រលាញ់គ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាព ព្រមទាំងកសាងគ្រួសារមួយដែលមានសាមគ្គីភាព និងប្រកបដោយសុភមង្គល
- ប្តី-ប្រពន្ធ មានសិទ្ធិជ្រើសរើសដោយសេរីនូវវិជ្ជាជីវៈរបស់ខ្លួន មានសិទ្ធិចូលរួមប្រាស្រ័យដោយសេរី ក្នុងសកម្មភាពនយោបាយ វប្បធម៌ និងសង្គម
- ប្តី-ប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់អាស្រ័យផល និងចាត់ចែងទ្រព្យសម្បត្តិរួម។ សហព័ទ្ធម្នាក់ៗ មានសិទ្ធិពេញលេញក្នុងការប្រើប្រាស់ និងអាស្រ័យផល និងចាត់ចែងទ្រព្យសម្បត្តិផ្ទាល់ខ្លួន
- សហព័ទ្ធម្នាក់ៗអាចប្រើប្រាស់សម្ភារៈដែលជាទ្រព្យសម្បត្តិរួមតាមតម្រូវការនៃសម្ភារៈនោះ។ សហព័ទ្ធទាំងត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមជាមួយគ្នា។ សហព័ទ្ធម្នាក់អាចទាមទារឱ្យសហព័ទ្ធម្នាក់ទៀតយល់ព្រមលើវិធានការចាំបាច់ ដើម្បីថែទាំទ្រព្យសម្បត្តិរួម ឬការរក្សាទុកតម្លៃទ្រព្យសម្បត្តិនោះ។ ទ្រព្យសម្បត្តិរួមអាចធ្វើការលក់ដូរ ឬធ្វើអំណោយបានលុះត្រាតែមានការព្រមព្រៀងពីសហព័ទ្ធទាំងពីរ។

យោងតាមការបកស្រាយខាងលើ ដើម្បីទទួលបានអាពាហ៍ពិពាហ៍ស្របច្បាប់បុរស និងនារីត្រូវគោរពតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ដែលមានចែងនៅក្នុង មាត្រា៩៤៨ និងមាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការរៀបរាប់របស់យើងខ្ញុំផ្នែកខាងលើ។ ប្រសិនបើការរៀបការ ឬរៀបអាពាហ៍ពិពាហ៍ គ្រាន់តែគោរពតាមប្រពៃណីដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ (អេតាស៊ីវិល) នោះចំណងអាពាហ៍ពិពាហ៍រវាងបុរស-នារីនោះនឹងត្រូវបានចាត់ទុកថាជា **ចំណងអនីតិសង្វាស**។ ហេតុនេះសម្រាប់ចំណងអនីតិសង្វាសនេះ យើងនឹងធ្វើការបកស្រាយនៅក្នុងព្រឹត្តបត្រគតិយុត្តភាគក្រោយ។

**ទំនាក់ទំនងមកកាន់៖**

**ការិយាល័យមេធាវី អេណា និងសហការី**

**គេហទំព័រ**: www.anna-associates.com

**អ៊ីមែល**: info@anna-associates.com

**លេខទូរស័ព្ទ**: (+៨៥៥) ៩៩ ៨៨៨ ៧៣៧

**អាសយដ្ឋានការិយាល័យ**: ជាន់ទី៧ អគារលេខ២៣៤ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*